**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខ: ០២១ ... ប្រ.ក ..... ប.ស្ថ

# ប្រកាស
## ស្តីពី
## ចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- យោងតាមការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១..**

ប្រកាសនេះមានគោលបំណងជួយសម្រួល និងផ្តល់ការណែនាំដល់ម្ចាស់គម្រោងអភិវឌ្ឍន៍ឯកជន និងសាធារណៈ ក្នុងការអនុវត្តនូវនីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ឱ្យមានប្រសិទ្ធភាព នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.**

ប្រកាសនេះមានគោលដៅ ធ្វើចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងអភិវឌ្ឍន៍ ដែលតម្រូវឱ្យមានកិច្ចសន្យាការពារបរិស្ថាន ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។

**ប្រការ៣.**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះប្រភេទគម្រោងអភិវឌ្ឍន៍ដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការរបស់បុគ្គលឯកជន ក្រុមហ៊ុនឯកជន ក្រុមហ៊ុនចម្រុះរដ្ឋ ឬក្រុមហ៊ុនរដ្ឋ ក្រសួង-ស្ថាប័នរដ្ឋ ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះ លើកលែងតែគម្រោងអភិវឌ្ឍន៍ដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ ដែលត្រូវសម្រេចដោយរាជរដ្ឋាភិបាល។

**ប្រការ៤.**

ប្រភេទគម្រោងអភិវឌ្ឍន៍ដែលតម្រូវឱ្យរៀបចំកិច្ចសន្យាការពារបរិស្ថាន គឺសំដៅដល់គម្រោងដែលមានការប៉ះពាល់តិចតួចដល់បរិស្ថាននិងសង្គម ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធ។ ករណីគម្រោងនេះមានការប៉ះពាល់មធ្យម ឬធ្ងន់ធ្ងរដល់បរិស្ថាននិងសង្គម នោះក្រសួងបរិស្ថានតម្រូវឱ្យម្ចាស់គម្រោងត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។

ចំពោះគម្រោងអភិវឌ្ឍន៍ដែលតម្រូវឱ្យរៀបចំកិច្ចសន្យាការពារបរិស្ថាន ម្ចាស់គម្រោងត្រូវភ្ជាប់មកជាមួយនូវផែនការគ្រប់គ្រងបរិស្ថាន។

**ប្រការ៥.**

ប្រភេទគម្រោងអភិវឌ្ឍន៍ដែលតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង គឺសំដៅដល់គម្រោងដែលមានការប៉ះពាល់មធ្យមដល់បរិស្ថាននិងសង្គម ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធ។ ករណីគម្រោងនេះមានការប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាននិងសង្គម នោះក្រសួងបរិស្ថានតម្រូវឱ្យម្ចាស់គម្រោងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។

**ប្រការ៦.**

ប្រភេទគម្រោងអភិវឌ្ឍន៍ដែលតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ គឺសំដៅដល់គម្រោងដែលមានការប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាននិងសង្គម ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធ។

**ប្រការ៧.**

រយៈពេលពិនិត្យ និងផ្តល់ការឯកភាពជាផ្លូវការលើកិច្ចសន្យាការពារបរិស្ថាន មានរយៈពេល ២៨ (ម្ភៃប្រាំបី) ថ្ងៃ នៃថ្ងៃធ្វើការ អនុលោមតាមប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងបរិស្ថាន រវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

រយៈពេលពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ត្រូវអនុលោមតាមអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

**ប្រការ៨.-**

ប្រភេទគម្រោងអភិវឌ្ឍន៍ដូចមានភ្ជាប់នៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះ អាចកែប្រែបានតាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**ប្រការ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព គ្រប់អគ្គនាយកនៃក្រសួងបរិស្ថាន អគ្គាធិការ ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងគ្រប់ប្រធានអង្គភាពចំណុះក្រសួងបរិស្ថាន ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ១០កើត ខែ មាឃ ឆ្នាំ ជូត ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១០ (ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ......០៤១ ប្រ.ក.......

ថ្ងៃ...ចន្ទ ១០កើត...ខែ...ផល្គុន...ឆ្នាំ...ជូត ឯកស័ក...ព.ស.២៥៦៣

ត្រូវនឹងថ្ងៃទី...០៣...ខែ...មីនា...ឆ្នាំ២០២០

## ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍

| ល.រ | ប្រភេទគម្រោង | ចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អនុលោមតាមទំហំនៃគម្រោងអភិវឌ្ឍន៍ | | |
|---|---|---|---|---|
| | | រ.ហ.ប.ស.ព | រ.ហ.ប.ស.ដ | កិច្ចសន្យាការពារបរិស្ថាន |
| ១. វិស័យរ៉ែ ថាមពល ឧស្សាហកម្ម | | | | |
| ១ | ការស្វែងរករកធនធានរ៉ែ និង/ឬប្រេងកាត និង/ឬឧស្ម័ន | | (គ្រប់ទំហំ) | |
| ២ | ការធ្វើអាជីវកម្មឧស្សាហកម្មធនធានរ៉ែ | (គ្រប់ទំហំ) | | |
| ៣ | ការធ្វើអាជីវកម្មរ៉ែប្រេងកាត និង/ឬឧស្ម័ន | (គ្រប់ទំហំ) | | |
| ៤ | ការធ្វើអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ មានដូចជា ថ្មកំបោរ ថ្មម៉ាប ថ្មកក់ ថ្មបំបែក ថ្មបាយក្រៀម ក្រួស ខ្សាច់ ឡាតេរីត អាចម៍ដី ដីឥដ្ឋ ហ្គ្រាណិត កៅឡាំង។ល។ | ( >40 ហិកតា) | (> 10 - 40 ហិកតា) | (≤ 10 ហិកតា) |
| ៥ | ការធ្វើអាជីវកម្មសិប្បកម្មធនធានរ៉ែ | | | ≤ 1 ហិកតា និង ជម្រៅ 5 ម៉ែត្រ |
| ៦ | រោងចក្រកែច្នៃរ៉ែមានតម្លៃ | (គ្រប់ទំហំ) | | |
| ៧ | មូលដ្ឋានលាងសម្អាតរ៉ែ | (គ្រប់ទំហំ) | | |
| ៨ | រោងចក្រផលិតឧស្ម័ន | (គ្រប់ទំហំ) | | |
| ៩ | រោងចក្រចម្រាញ់ប្រេងកាត | (គ្រប់ទំហំ) | | |
| ១០ | រោងចក្រគីមីប្រេងកាត | (គ្រប់ទំហំ) | | |
| ១១ | សំណង់បង្ហូរប្រេង និង/ឬឧស្ម័ន | (ប្រវែង ≥ 2 គ.ម) | | |
| ១២ | កន្លែងផ្ទុកប្រេងឥន្ធនៈ និង/ឬហ្គាស សម្រាប់ចែកចាយ ឬមណ្ឌលសន្និធិប្រេងឥន្ធនៈ និង/ឬហ្គាស | (> 1 000 000 លីត្រ) | (60 000 - ≤1 000 000 លីត្រ) | |
| ១៣ | ស្ថានីយប្រេងឥន្ធនៈ និង/ឬហ្គាស ឬមណ្ឌលសន្និធិប្រេងឥន្ធនៈ និង/ឬហ្គាស | (> 60 000 លីត្រ) | (> 40 000 - 60 000 លីត្រ) | (≥ 8 000 - 40 000 លីត្រ) |
| ១៤ | រោងចក្រស៊ីម៉ងត៍ | (គ្រប់ទំហំ) | | |
| ១៥ | រោងចក្រវារីអគ្គិសនី | (>50 មេហ្គាវ៉ាត់) | (≥ 1 - 50 មេហ្គាវ៉ាត់) | (< 1 មេហ្គាវ៉ាត់) |
| ១៦ | រោងចក្រអគ្គិសនី | (>50 មេហ្គាវ៉ាត់) | (≥ 5 - 50 មេហ្គាវ៉ាត់) | (< 5 មេហ្គាវ៉ាត់) |

| | | | | |
|---|---|---|---|---|
| ១៧ | គម្រោងសាងសង់អនុស្ថានីយអគ្គិសនី | | (គ្រប់ទំហំ) | |
| ១៨ | រោងចក្រផលិតជីគីមី | (គ្រប់ទំហំ) | | |
| ១៩ | រោងចក្រផលិតថ្នាំលាបគ្រប់ប្រភេទ | (គ្រប់ទំហំ) | | |
| ២០ | រោងចក្រគីមី | (គ្រប់ទំហំ) | | |
| ២១ | រោងចក្រកែច្នៃលោហៈគ្រប់ប្រភេទ ដែកគោល លួសបន្លាសំណាញ់ | (≥ 300 តោន/ខែ) | | |
| ២២ | រោងចក្រស្លលោហៈគ្រប់ប្រភេទ | (គ្រប់ទំហំ) | | |
| ២៣ | រោងចក្រផលិតដែក H និងសម្ភារផ្សេងៗ | (គ្រប់ទំហំ) | | |
| ២៤ | រោងចក្រផលិតប្រេងម៉ាស៊ូតធម្មជាតិ | (គ្រប់ទំហំ) | | |
| ២៥ | រោងចក្រផលិតប្រេងអេតាណុល/មេតាណុល | (គ្រប់ទំហំ) | | |
| ២៦ | រោងចក្រចម្រាញ់ប្រេងខ្មៅពីសំបកកៅស៊ូកង់រថយន្តចាស់ៗ | (គ្រប់ទំហំ) | | |
| ២៧ | រោងចក្រផលិតអាគុយ និងថ្មពិល | (គ្រប់ទំហំ) | | |
| ២៨ | រោងចក្រផលិតស្រា ស្រាបៀរ អាល់កុល | (គ្រប់ទំហំ) | | |
| ២៩ | រោងចក្រផលិតបារី ថ្នាំជក់ | (គ្រប់ទំហំ) | | |
| ៣០ | រោងចក្រផលិតថ្មស្មុយ | (គ្រប់ទំហំ) | | |
| ៣១ | រោងចក្រផលិតខ្លាញ់គោ ប្រេងម៉ាស៊ីន | (គ្រប់ទំហំ) | | |
| ៣២ | រោងចក្រផលិតក្រដាស | (គ្រប់ទំហំ) | | |
| ៣៣ | រោងចក្រផលិតម្សៅក្រដាស និងកែច្នៃក្រដាស | (គ្រប់ទំហំ) | | |
| ៣៤ | រោងចក្រសម្លាប់ស្បែក កែច្នៃស្បែក ធ្វើការស្បែកសត្វ | (គ្រប់ទំហំ) | | |
| ៣៥ | រោងចក្រផលិតជីសរីរាង្គ | | (គ្រប់ទំហំ) | |
| ៣៦ | រោងចក្រផលិតសម្ភារបរិក្ខារអគ្គិសនី និងអេឡិចត្រូនិចគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ៣៧ | រោងចក្រផលិត និងផ្គុំដំឡើងគ្រឿងម៉ាស៊ីន សម្ភារបរិក្ខារឧស្សាហកម្ម និងមុខសញ្ញាពាក់ព័ន្ធផ្សេងទៀត | | (គ្រប់ទំហំ) | |
| ៣៨ | រោងចក្រផលិតគ្រឿងយន្ត | | (គ្រប់ទំហំ) | |
| ៣៩ | រោងចក្រប្លាស្ទិក | | (គ្រប់ទំហំ) | |
| ៤០ | រោងចក្រកែច្នៃកម្ទេចប្លាស្ទិក និងផលិតផលពីប្លាស្ទិក | | (គ្រប់ទំហំ) | |
| ៤១ | រោងចក្រផលិតថ្នាំសម្លាប់សត្វល្អិត | | (គ្រប់ទំហំ) | |
| ៤២ | រោងចក្រផលិតម្សៅសាប៊ូ សាប៊ូដុំ សាប៊ូទឹក | | (គ្រប់ទំហំ) | |

| | | | | |
|---|---|---|---|---|
| ៤៣ | រោងចក្រកែច្នៃសំណល់ ដុតសំណល់ | | (គ្រប់ទំហំ) | |
| ៤៤ | រោងចក្រតម្បាញ ជ្រលក់ពណ៌ | | (គ្រប់ទំហំ) | |
| ៤៥ | រោងចក្រកាត់ដេរ បោកគក់ បោះពុម្ព ជ្រលក់ពណ៌ | | (គ្រប់ទំហំ) | |
| ៤៦ | រោងចក្រផលិតអេប៉ុង កៅស៊ូមូស | | (គ្រប់ទំហំ) | |
| ៤៧ | រោងចក្រផលិតកាំជ្រួច និងសារធាតុផ្ទុះ សម្រាប់អុជលម្អក្នុងពិធីបុណ្យនិងពិធីផ្សេងៗ | | (គ្រប់ទំហំ) | |
| ៤៨ | រោងចក្រចម្រាញ់ផ្ទុងប្រេង | | (គ្រប់ទំហំ) | |
| ៤៩ | រោងចក្រកែច្នៃដំឡូងមី និងកែច្នៃផលិតផលផ្សេងៗ | | (គ្រប់ទំហំ) | |
| ៥០ | រោងចក្រផលិតខ្សែ ខ្សែរូតគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ៥១ | រោងចក្រកាត់ដេរសម្លៀកបំពាក់ ធ្វើពីរោមសត្វ ស្បែកសត្វ កែច្នៃរោមសត្វ និងស្បែកជាប់រោមសត្វ | | (គ្រប់ទំហំ) | |
| ៥២ | រោងចក្រផលិតសំបកកំប៉ុងពីអាលុយមីញ៉ូម | | (គ្រប់ទំហំ) | |
| ៥៣ | រោងចក្រផលិតម្សៅមី | | (គ្រប់ទំហំ) | |
| ៥៤ | រោងចក្រចិញ្ច្រាំដើមអាកាស្យា និងដើមប្រេងខ្យល់ | | (គ្រប់ទំហំ) | |
| ៥៥ | រោងចក្រផលិតកៅ ដបគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ៥៦ | មូលដ្ឋានផលិតឥដ្ឋក្រាល ឥដ្ឋការ៉ូ | | (គ្រប់ទំហំ) | |
| ៥៧ | រោងចក្រផលិតធ្យូង(ចេញពីកាកអំពៅ គ្រឡោកដូង អង្កាម) | | (គ្រប់ទំហំ) | |
| ៥៨ | រោងចក្រកៅស៊ូក្រែប / កែច្នៃកៅស៊ូ | | (≥ 1 000 តោន/ឆ្នាំ) | (< 1 000 តោន/ឆ្នាំ) |
| ៥៩ | រោងចក្រផលិត និងកែច្នៃអំបិល | | (≥ 3 000 តោន/ឆ្នាំ) | (< 3 000 តោន/ឆ្នាំ) |
| ៦០ | មូលដ្ឋានលាយបេតុង | | (> 30 000 ម៉ែត្រគូប/ខែ) | (≤ 30 000 ម៉ែត្រគូប/ខែ) |
| ៦១ | មូលដ្ឋានផលិតលូ និងគ្រឿងសំណង់បេតុង | | (> 30 000 ម៉ែត្រគូប/ខែ) | (≤ 30 000 ម៉ែត្រគូប/ខែ) |
| ៦២ | រោងចក្រផលិតស្ករស | | (≥ 3 000 តោន/ឆ្នាំ) | (< 3 000 តោន/ឆ្នាំ) |
| ៦៣ | រោងចក្រក្តារបន្ទះ | | (≥ 100 000 ម៉ែត្រគូប/ឆ្នាំ ឈើមូល) | (< 100 000 ម៉ែត្រគូប/ឆ្នាំ ឈើមូល) |
| ៦៤ | រោងចក្រអារឈើ | | (≥ 50 000 ម៉ែត្រគូប/ឆ្នាំ ឈើមូល) | (< 50 000 ម៉ែត្រគូប/ឆ្នាំ ឈើមូល) |

| | | | | |
|---|---|---|---|---|
| ៦៥ | រោងចក្រផលិតកៅស៊ូកង់ និងពោះវៀនកង់គ្រប់ប្រភេទ | | (≥ 500 តោន/ឆ្នាំ) | (< 500 តោន/ឆ្នាំ) |
| ៦៦ | រោងចក្រផលិតចំណីសត្វ | | (≥ 10 000 តោន/ឆ្នាំ) | (< 10 000 តោន/ឆ្នាំ) |
| ៦៧ | រោងចក្រផលិតម្ហូបអាហារ និងគ្រឿងកំប៉ុង | | (≥ 500 តោន/ឆ្នាំ) | (< 500 តោន/ឆ្នាំ) |
| ៦៨ | រោងចក្រផលិតភេសជ្ជៈ ទឹកផ្លែឈើគ្រប់ប្រភេទ | | (គ្រប់ទំហំ) | |
| ៦៩ | រោងចក្រផលិតតំណាប់ផ្លែឈើ | | (≥ 500 តោន/ឆ្នាំ) | (< 500 តោន/ឆ្នាំ) |
| ៧០ | រោងចក្រ ឬម៉ាស៊ីនកិនស្រូវ និងគ្រាប់ធញ្ញជាតិ / រោងចក្រកែច្នៃស្រូវ និងគ្រាប់ធញ្ញជាតិ | | | (≥ 3 000 តោន/ឆ្នាំ) |
| ៧១ | រោងចក្រផលិតទឹកត្រី ស៊ីអ៊ីវ សៀង ម្ទេស ប៉េងប៉ោះ | | | (≥ 500 000 លីត្រ/ឆ្នាំ) |
| ៧២ | មូលដ្ឋានផលិតគ្រឿងសង្ហារិម | | | (≥ 1 000 ម៉ែត្រគូប/ឆ្នាំ ឈើមូល) |
| ៧៣ | រោងចក្រផលិតសសរគ្រឹះ និងបង្គោលភ្លើង | | | (គ្រប់ទំហំ) |
| ៧៤ | រោងចក្រដំឡើងគ្រឿងយន្ត | | | (គ្រប់ទំហំ) |
| ៧៥ | រោងចក្រផលិតសំឡី | | | (គ្រប់ទំហំ) |
| ៧៦ | មូលដ្ឋានជួសជុលគ្រឿងយន្ត និងនាវា | | | (គ្រប់ទំហំ) |
| ៧៧ | មូលដ្ឋាន ឬស្ថានីយផលិតទឹកស្អាតប្រើប្រាស់ និងប្រព័ន្ធចែកចាយ | | | (គ្រប់ទំហំ) |
| ៧៨ | មូលដ្ឋានផលិតឥដ្ឋក្បឿង | | | (គ្រប់ទំហំ) |
| ៧៩ | រោងចក្រផលិតម្សៅអង្ករ | | | (គ្រប់ទំហំ) |
| ៨០ | រោងចក្រផ្គុំដំឡើងសម្ភារបរិក្ខារអគ្គិសនី និងអេឡិចត្រូនិចគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ៨១ | រោងចក្រដំឡើងឧបករណ៍លើកដាក់ទំនិញ | | | (គ្រប់ទំហំ) |
| ៨២ | រោងចក្រផលិតឆ័ត្រ | | | (គ្រប់ទំហំ) |
| ៨៣ | រោងចក្រផលិតស្ករគ្រាប់ | | | (គ្រប់ទំហំ) |
| ៨៤ | រោងចក្រផលិតស្បែកជើង | | | (គ្រប់ទំហំ) |
| ៨៥ | រោងចក្រផលិតកាបូបគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |

| | | | | |
|---|---|---|---|---|
| ៨៦ | រោងចក្រផលិតសម្ភារកីឡា | | | (គ្រប់ទំហំ) |
| ៨៧ | រោងចក្រផលិតពូក | | | (គ្រប់ទំហំ) |
| ៨៨ | រោងចក្រផលិតកាបូប កន្សែង មុង និងតុក្កតា | | | (គ្រប់ទំហំ) |
| ៨៩ | រោងចក្រផលិតផលវេចខ្ចប់សម្រាប់នាំចេញ | | | (គ្រប់ទំហំ) |
| ៩០ | រោងចក្រផលិតស្រោមដៃ ស្រោមជើង កន្សែង មួក | | | (គ្រប់ទំហំ) |
| ៩១ | រោងចក្រផលិតខ្សែយឺតចង្កេះខោសម្រាប់ផ្គត់ផ្គង់ | | | (គ្រប់ទំហំ) |
| ៩២ | រោងចក្រផលិតកេសកាតុង | | | (គ្រប់ទំហំ) |
| ៩៣ | រោងចក្រផលិតអំបោះ ខារអំបោះដេរ ផលិតស្តុតបិត | | | (គ្រប់ទំហំ) |
| ៩៤ | រោងចក្រផលិតសក់សិប្បនិម្មិត | | | (គ្រប់ទំហំ) |
| ៩៥ | រោងចក្រផលិតទ្វារ និងកញ្ចក់ក្បាច់ | | | (គ្រប់ទំហំ) |
| ៩៦ | រោងចក្រផលិតបន្ទះកម្រាល បន្ទះជញ្ជាំង បន្ទះហ៊ីប្រូ និងក្បឿង | | | (គ្រប់ទំហំ) |
| ៩៧ | រោងចក្រផលិតសម្ភារការិយាល័យគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ៩៨ | រោងចក្រផលិតស័ង្កសី ទ្វាររមូរ និងដែកសំណង់ | | | (គ្រប់ទំហំ) |
| ៩៩ | រោងចក្រផលិតផ្លាកសញ្ញាសម្លៀកបំពាក់ | | | (គ្រប់ទំហំ) |
| ១០០ | រោងចក្រផលិតទឹកតែត្រជាក់ និងទឹកដោះគោជូរ | | | (គ្រប់ទំហំ) |
| ១០១ | រោងចក្រផលិតក្រដាសអនាម័យ | | | (គ្រប់ទំហំ) |
| ១០២ | រោងចក្រផលិតសម្ភារស្ទូចត្រីគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១០៣ | រោងចក្រផលិតទ្រនាប់កាត់ពុម្ពស្បែកជើង | | | (គ្រប់ទំហំ) |
| ១០៤ | រោងចក្រផលិតអាវភ្លៀងគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១០៥ | រោងចក្រសម្ងួតគ្រាប់ធញ្ញជាតិ | | | (គ្រប់ទំហំ) |
| ១០៦ | រោងចក្រផលិតរនាំងស្លាបព្រិល និងរបាំងបង្អួចគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១០៧ | រោងចក្រកាត់ដេរសម្លៀកបំពាក់ | | | (គ្រប់ទំហំ) |
| ១០៨ | រោងចក្រផលិតសម្ភារបំពាក់រថយន្ត | | | (គ្រប់ទំហំ) |
| ១០៩ | រោងចក្រផលិតទឹកសុទ្ធ | | | (គ្រប់ទំហំ) |
| ១១០ | រោងចក្រផលិតស្រោមកែវ ស្រោមដប | | | (គ្រប់ទំហំ) |
| ១១១ | រោងចក្រផលិតគ្រឿងសម្ភារថែរក្សាសម្ផស្ស | | | (គ្រប់ទំហំ) |
| ១១២ | រោងចក្រផលិតប្រដាប់ព្យួរសម្លៀកបំពាក់ និងផលិតផលពីប្លាស្ទិកគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១១៣ | រោងចក្រផលិតបំពង់ទីប | | | (គ្រប់ទំហំ) |

| | | | | |
|---|---|---|---|---|
| [illegible] | [illegible]ិតសម្ភារប្រើប្រាស់ក្នុងផ្ទះបាយ និងផលិតផល [illegible]លម្អគ្រឿងសង្ហារិម (ពីក្រដាស និងក្រណាត់) | | | (គ្រប់ទំហំ) |
| ១១៥ | រោងចក្រផលិតចាន ឆ្នាំង ប៉ាន់តែ ពែង និងសម្ភារផ្សេងៗ | | | (គ្រប់ទំហំ) |
| ១១៦ | រោងចក្រផលិតវត្ថុអនុស្សាវរីយ៍ និងប្រដាប់វេចខ្ចប់ | | | (គ្រប់ទំហំ) |
| ១១៧ | រោងចក្រផលិតនំបញ្ចុក និងមីកញ្ចប់គ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១១៨ | រោងចក្រផលិតខ្សែក្រវ៉ាត់គ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១១៩ | រោងចក្រកម្រាលតុ កម្រាលពូក និងស្រោមខ្នើយ | | | (គ្រប់ទំហំ) |
| ១២០ | រោងចក្រផលិតគ្រឿងបន្សំស្បែកជើង | | | (គ្រប់ទំហំ) |
| ១២១ | រោងចក្រផលិតគ្រឿងតុបតែងរថយន្ត | | | (គ្រប់ទំហំ) |
| ១២២ | រោងចក្រផលិតគ្រឿងបន្សំសម្លៀកបំពាក់ | | | (គ្រប់ទំហំ) |
| ១២៣ | រោងចក្រផលិត និងផ្គុំដំឡើងឧបករណ៍បញ្ចូលភ្លើងកុំព្យូទ័រ និងទូរស័ព្ទ | | | (គ្រប់ទំហំ) |
| ១២៤ | រោងចក្រផលិតរានទេវតា | | | (គ្រប់ទំហំ) |
| ១២៥ | រោងចក្រផលិតទៀន | | | (គ្រប់ទំហំ) |
| ១២៦ | រោងចក្រផលិតបាវ | | | (គ្រប់ទំហំ) |
| ១២៧ | រោងចក្រផលិតទឹកកក | | | (គ្រប់ទំហំ) |
| ១២៨ | រោងចក្រផលិត និងផ្គុំដំឡើងឧបករណ៍ជាងគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១២៩ | រោងចក្រផលិតសម្ភារបរិក្ខារបម្រើឱ្យវិស័យសំណង់ | | | (គ្រប់ទំហំ) |
| ១៣០ | អាជីវកម្មប្រមូលទិញ ស្តុក និងកែច្នៃសំបកកង់យានយន្តគ្រប់ប្រភេទ | | | (គ្រប់ទំហំ) |
| ១៣១ | មូលដ្ឋានកិនជ័រ និងផលិតគ្រាប់ជ័រ | | | (គ្រប់ទំហំ) |
| ២. វិស័យសុខាភិបាល | | | | |
| ១៣២ | មន្ទីរពេទ្យ | (គ្រប់ទំហំ) | | |
| ១៣៣ | មន្ទីរពេទ្យបង្អែក | | (គ្រប់ទំហំ) | |
| ១៣៤ | មន្ទីរពិសោធន៍ | | (គ្រប់ទំហំ) | |
| ១៣៥ | មណ្ឌលលាងឈាម | | (គ្រប់ទំហំ) | |
| ១៣៦ | រោងចក្រផលិតសម្ភារបរិក្ខារពេទ្យ | | (គ្រប់ទំហំ) | |
| ១៣៧ | រោងចក្រផលិតឱសថ | | (គ្រប់ទំហំ) | |
| ១៣៨ | រោងចក្រផលិតវត្ថុធាតុដើមសម្រាប់ផលិតឱសថ | | (គ្រប់ទំហំ) | |

| | | | | |
|---|---|---|---|---|
| ១៣៩ | មន្ទីរពហុព្យាបាល មន្ទីរព្យាបាល សម្ភព | | | (គ្រប់ទំហំ) |
| ១៤០ | មណ្ឌលសុខភាព | | | (គ្រប់ទំហំ) |
| ១៤១ | ឃ្លាំងឱសថ | | | (គ្រប់ទំហំ) |
| ៣. វិស័យធនធានទឹក | | | | |
| ១៤២ | ប្រព័ន្ធស្រោចស្រព | | (≥ 5 000 ហិកតា) | (1000 - < 5000 ហិកតា) |
| ១៤៣ | ប្រព័ន្ធរំដោះទឹក | | (≥ 5 000 ហិកតា) | (1000 - < 5000 ហិកតា) |
| ៤. វិស័យកសិកម្ម | | | | |
| ១៤៤ | ផ្ទៃដីលិចទឹក និងដីតំបន់ឆ្នេរ | (គ្រប់ទំហំ) | | |
| ១៤៥ | អាជីវកម្មព្រៃគប់ | (≥ 500 ហិកតា) | | (< 500 ហិកតា) |
| ១៤៦ | ផ្ទៃដីដែលមានព្រៃឈើ | (≥ 500 ហិកតា) | | (< 500 ហិកតា) |
| ១៤៧ | ផ្ទៃដីដំណាំកសិកម្ម ឧស្សាហកម្ម | (≥ 500 ហិកតា) | | (< 500 ហិកតា) |
| ១៤៨ | ព្រៃសម្បទាន | (≥ 500 ហិកតា) | | (< 500 ហិកតា) |
| ១៤៩ | ផែនសាទ លើកលែងចំពោះផែនសាទលក្ខណៈគ្រួសារ | | (គ្រប់ទំហំ) | |
| ១៥០ | កសិដ្ឋានចិញ្ចឹមសត្វមាន់ ទា និងប្រភេទបក្សីចិញ្ចឹមយកសាច់ និង/ឬស៊ុត ផ្សេងៗទៀត | | (≥ 50 000 ក្បាល) | (5 000 - < 50 000 ក្បាល) |
| ១៥១ | កសិដ្ឋានចិញ្ចឹមសត្វគោ ក្របី ជ្រូក ចៀម ពពែ សេះ ស្វា និងសត្វចិញ្ចឹមយកសាច់ និង/ឬទឹកដោះ ផ្សេងៗទៀត | | (≥ 500 ក្បាល) | (100 - < 500 ក្បាល) |
| ១៥២ | កសិដ្ឋានចិញ្ចឹមសត្វក្រពើ អណ្តើក កន្ធាយ | | (≥ 500 ក្បាល) | (100 - < 500 ក្បាល) |
| ១៥៣ | វារីវប្បកម្មចិញ្ចឹមត្រី ក្តាម បង្គា បង្កង និងវារីវប្បកម្មផ្សេងៗទៀត | | (≥ 10 ហិកតា) | (5 - < 10 ហិកតា) |
| ១៥៤ | វារីវប្បកម្មដាំសារាយ | | (≥ 20 ហិកតា) | (5 - < 20 ហិកតា) |
| ១៥៥ | ស្ពាន និងអភិវឌ្ឍន៍ដំណាំកសិកម្ម ឧស្សាហកម្ម | | (≥ 500 ហិកតា) | (< 500 ហិកតា) |
| ១៥៦ | ទីសត្តឃាត | | (≥ 100 ក្បាល/ថ្ងៃ) | (10 - < 100 ក្បាល/ថ្ងៃ) |
| ១៥៧ | ឃ្លាំងស្តុកថ្នាំ និងជីកសិកម្ម | | | (≥ 10 000 តោន/ឆ្នាំ) |
| ៥. វិស័យទេសចរណ៍ | | | | |
| ១៥៨ | តំបន់ទេសចរណ៍ | (> 50 ហិកតា) | (> 10 - 50 ហិកតា) | (≤ 10 ហិកតា) |

| | | | | |
|---|---|---|---|---|
| ១៥៩ | អាជីវកម្មខាត់អូខេ រង្គសាល និងនីស្ដូតែក | (ផ្ទៃក្រឡាសំណង់ > 45 000 ម៉ែត្រការ៉េ) | (ផ្ទៃក្រឡាសំណង់ > 15 000-45 000 ម៉ែត្រការ៉េ) | (ផ្ទៃក្រឡាសំណង់ > 3 000 - 15 000 ម៉ែត្រការ៉េ) |
| ១៦០ | ទីលានវាយកូនគោល | | (≥ 18 រន្ធ) | (< 18 រន្ធ) |
| ១៦១ | បង្កើតសួនសត្វ | | (≥ 10 ហិកតា) | (< 10 ហិកតា) |
| ១៦២ | ភោជនីយដ្ឋាន | | (> 500 កៅអី) | (> 100 - 500 កៅអី) |
| ១៦៣ | កំពង់ផែទេសចរណ៍ | | (គ្រប់ទំហំ) | |
| ១៦៤ | ភោជនីយដ្ឋានបណ្តែតទឹក | | | (≥ 300 កៅអី) |
| ១៦៥ | បៀរហ្គាដេន | | | (គ្រប់ទំហំ) |
| ១៦៦ | អាហារដ្ឋានទេសចរណ៍ | | | (≥ 300 កៅអី) |
| ៦. វិស័យហេដ្ឋារចនាសម្ព័ន្ធ | | | | |
| ១៦៧ | សំណង់អាកាសយានដ្ឋាន | (គ្រប់ទំហំ) | | |
| ១៦៨ | ការអភិវឌ្ឍទីក្រុង | (គ្រប់ទំហំ) | | |
| ១៦៩ | ការសាងសង់ពហុកីឡដ្ឋាន | (គ្រប់ទំហំ) | | |
| ១៧០ | ទីលានចាក់សំណល់ឧស្សាហកម្ម | (គ្រប់ទំហំ) | | |
| ១៧១ | តំបន់ឧស្សាហកម្ម/តំបន់សេដ្ឋកិច្ចពិសេស | (គ្រប់ទំហំ) | | |
| ១៧២ | មូលដ្ឋានប្រព្រឹត្តកម្មបែបបយន្តកម្ម និងប្រព័ន្ធបណ្តាញលូ | (គ្រប់ទំហំ) | | |
| ១៧៣ | សំណង់ផ្លូវដែក | (គ្រប់ទំហំ) | | |
| ១៧៤ | សំណង់កំពង់ផែ លើកលែងតែសំណង់កំពង់ផែជាលក្ខណៈគ្រួសារ | (គ្រប់ទំហំ) | | |
| ១៧៥ | ស្ថាបនា និងប្រតិបត្តិការខ្សែកាបក្រោមបាតសមុទ្រ និងហេដ្ឋារចនាសម្ព័ន្ធ រាប់បញ្ចូលទាំងការភ្ជាប់ខ្សែកាបពីសមុទ្រឡើងគោក | (គ្រប់ទំហំ) | | |
| ១៧៦ | សំណង់អគារគ្រប់ប្រភេទ (សំណង់អគារការិយាល័យ សំណង់អគារពហុវិស័យ សំណង់អគារពាណិជ្ជកម្ម សំណង់អគារខុនដូ សំណង់បុរី សំណង់ផ្ទះល្វែងនិងវីឡា សំណង់អគារផ្សារទំនើប និងសំណង់អគារផ្សេងៗ) | (ផ្ទៃក្រឡាសំណង់ > 45 000 ម៉ែត្រការ៉េ) | (ផ្ទៃក្រឡាសំណង់ > 15 000-45 000 ម៉ែត្រការ៉េ) | (ផ្ទៃក្រឡាសំណង់ > 3 000 - 15 000 ម៉ែត្រការ៉េ) |
| ១៧៧ | សំណង់សណ្ឋាគារតំបន់ឆ្នេរ/មាត់ទន្លេ | (> 230 បន្ទប់) | (≥ 60 - 230 បន្ទប់) | (< 60 បន្ទប់) |

| | | | | |
|---|---|---|---|---|
| ១៧៨ | សំណង់សណ្ឋាគារក្រៅពីតំបន់ឆ្នេរ និងមាត់ទន្លេ | (> 250 បន្ទប់) | (≥80 - 250 បន្ទប់) | (< 80 បន្ទប់) |
| ១៧៩ | សំណង់ផ្លូវថ្នល់ | (> 100 គម) | (≥ 30 - 100 គម) | (10 - < 30 គម) |
| ១៨០ | សំណង់ពង្រីកផ្លូវថ្នល់ ផ្លូវដែក | (> 100 គម) | (≥ 50 - 100 គម) | (10 - < 50 គម) |
| ១៨១ | សំណង់ផ្លូវនៅក្នុងតំបន់ការពារធម្មជាតិ | (> 30 គម) | (≥ 10 - 30 គម) | (< 10 គម) |
| ១៨២ | សំណង់ជួសជុល ពង្រីកផ្លូវនៅក្នុងតំបន់ការពារធម្មជាតិ | (> 50 គម) | (≥ 10 - 50 គម) | (< 10 គម) |
| ១៨៣ | បណ្តាញខ្សែបញ្ជូនថាមពលអគ្គិសនី | (> 230 គីឡូវ៉ុល) | (≥ 115 – 230 គីឡូវ៉ុល) | (< 115 គីឡូវ៉ុល) |
| ១៨៤ | ការបូមភក់ ល្បាប់ | (≥ 50 000 ម៉ែត្រគូប) | | (< 50 000 ម៉ែត្រគូប) |
| ១៨៥ | សំណង់ផ្ទះសំណាក់ | | (≥ 80 បន្ទប់) | (< 80 បន្ទប់) |
| ១៨៦ | នាវាចរណ៍ | | (≥ 100 តោន) | (< 100 តោន) |
| ១៨៧ | មូលដ្ឋានប្រព្រឹត្តកម្មបែបធម្មជាតិ និងប្រព័ន្ធបណ្តាញលូ | | (គ្រប់ទំហំ) | |
| ១៨៨ | ទីលានចាក់សំរាម | | (គ្រប់ទំហំ) | |
| ១៨៩ | សំណង់ស្ពានថ្នល់ | | (ទ្រទម្ងន់ ≥ 30 តោន) | |
| ១៩០ | បណ្តាញបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន | | (គ្រប់ទំហំ) | |
| ១៩១ | បណ្តាញខ្សែកាបអុបទិកលើគោក | | (គ្រប់ទំហំ) | |
| ១៩២ | មជ្ឈមណ្ឌលទិន្នន័យ | | (គ្រប់ទំហំ) | |
| ១៩៣ | មជ្ឈមណ្ឌលពិសោធន៍ រួមមានការត្រួតពិនិត្យគុណភាព បច្ចេកទេស និងការបញ្ជាក់វិញ្ញាបនបត្រ | | (គ្រប់ទំហំ) | |
| ១៩៤ | សេវាទូរគមនាគមន៍មូលដ្ឋាន (ទូរស័ព្ទចល័ត ទូរស័ព្ទអចល័ត អ៊ីនធើណេត និងសេវាផ្តល់អត្ថប្រយោជន៍បន្ថែម) | | | (គ្រប់ទំហំ) |
| ១៩៥ | គម្រោងសាងសង់ស្តង់-តូប និងផ្សាររមេឃ | | | (គ្រប់ទំហំ) |
| ១៩៦ | ទីតាំងដំឡើងប្រព័ន្ធទូរស័ព្ទ | | | (គ្រប់ទំហំ) |
| ១៩៧ | ទីលានបញ្ចុះសព | | | (≥ 5 ហិកតា) |

សម្គាល់៖

- រ.ហ.ប.ស.ព ៖ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ
- រ.ហ.ប.ស.ដ ៖ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង